ខុមហ្វ្រែល COMFREL

# បោះឆ្នោតគាំទ្រស្ត្រីជួយប្រទេសយើង



## ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៥
## ថ្ងៃអាទិត្យ ទី២៨ ខែកក្កដា ឆ្នាំ២០១៣

ចេញផ្សាយ ខែធ្នូ ឆ្នាំ២០១២

# តួអង្គសំខាន់ៗ៖



លោកពូ សម
ជាតំណាងអង្គការខុមប្រែល



លោក ចំរើន
ជាមនុស្សសកម្មក្នុងឃុំ



មីង ចំណាន ជាស្ត្រីសកម្ម



សុជាតិ
ជាសកម្មជនឃុំ ខុមប្រែល



លោក ដារ៉ា
ជាអ្នកចេះដឹងក្នុងឃុំ



លោកតាដេញចាប៉ី
ជាព្រឹទ្ធាចារ្យយល់ដឹងច្រើន



ស្រី កែវ ជានិស្សិត



ស្រី ពេជ្រ ជានិស្សិត



ស្រី ឌីន ជានិស្សិត



ឧត្តម ជានិស្សិត



ពន្លក ជានិស្សិត

## សង្ខេបរឿង៖

**តើត្រូវធ្វើយ៉ាងម៉េច ទើបបោះឆ្នោតឲ្យជាប់ស្ត្រី?**
អ្នកបោះឆ្នោតត្រូវតាមដាន សង្កេត ពិនិត្យមើល ដូចតទៅ៖

- ទី១ យើងត្រូវពិនិត្យមើលបញ្ជីបេក្ខជនឈរឈ្មោះគណបក្សនយោបាយ ថាតើមានដាក់បេក្ខជនស្ត្រី-បុរសឆ្លាស់គ្នាដែរឬទេ ពិសេសនៅជួរលើ! ព្រោះអ្នកដែលនៅលេខរៀងខាងលើអាចមានលទ្ធភាពជាប់ច្រើន។

- ទី២ ត្រូវពិនិត្យកម្មវិធីនយោបាយ ថាតើគណបក្សណាខ្លះលើកស្ទួយ និងផ្តល់ឱកាសឲ្យស្ត្រី? មានគោលនយោបាយជាក់លាក់គិតគូរដោះស្រាយបញ្ហាស្ត្រី និងកុមារដែរឬទេ? ដូចជាបញ្ហាជួញដូរស្ត្រី និងកុមារ បញ្ហាសុខភាព អំពើហិង្សាក្នុងគ្រួសារ ការរំលោភសេពសន្ថវៈ ការរើសអើងក្នុងការងារ ។ល។ និង។ល។

- ទី៣ តើគណបក្សនោះគោរព និងធ្វើតាមការសន្យារបស់ខ្លួនបានកម្រិតណា?

**ឧទាហរណ៍** មុនជាប់ឆ្នោត សន្យាថានឹងធ្វើនេះធ្វើនោះ ពេលជាប់ឆ្នោត បំភ្លេចការសន្យា ឬធ្វើបានតិចតួច ភូតភរប្រជាពលរដ្ឋញយៗ យើងជាអ្នកបោះឆ្នោតត្រូវតែឈប់គាំទ្រ (ឈប់បោះឆ្នោតឲ្យ) តទៅទៀត។

**សារៈសំខាន់ស្ត្រីជាអ្នកដឹកនាំ**

- បញ្ហារបស់ស្ត្រី កុមារ នឹងត្រូវបានដោះស្រាយ នៅពេលមានចំនួនស្ត្រីច្រើនចូលរួមក្នុងការដឹកនាំ និងការសម្រេចចិត្ត។

- នៅពេលស្ត្រីក្លាយជាអ្នកដឹងនាំ ស្ត្រីនឹងមានឱកាសលើកឡើងពីតម្រូវការចាំបាច់របស់ស្ត្រី ដាក់បញ្ចូលទៅក្នុងគោលនយោបាយនានារបស់ជាតិ។

- អាចឆ្លើយតបតម្រូវការ និងបញ្ហាស្ត្រីបាន ព្រោះអ្នកដែលអាចមើលឃើញបញ្ហា និងដឹងពីតម្រូវការចាំបាច់របស់ស្ត្រី គឺមាន**តែស្ត្រីខ្លួនឯង**ប៉ុណ្ណោះ។

**សូមបោះឆ្នោតឲ្យស្ត្រី បញ្ហាសិទ្ធិស្ត្រី និងកុមារនឹងត្រូវបានដោះស្រាយ!**

# វិធានការនានា ដើម្បីផ្តល់ឱកាសឲ្យស្ត្រីចូលរួម ក្នុងនយោបាយ និងកិច្ចការសង្គម

មាត្រា៣ នៃអនុសញ្ញាស៊ី-ដបានចែងថា "ក្នុងគ្រប់វិស័យ ជាពិសេស វិស័យនយោបាយ សង្គមកិច្ច សេដ្ឋកិច្ច និងវប្បធម៌ រដ្ឋត្រូវចាត់វិធានការសមស្របទាំងអស់ រួមមានការធ្វើច្បាប់ផង ដើម្បីធានាការអភិវឌ្ឍន៍ និងការរីកចម្រើនពេញលេញរបស់ស្ត្រី ដើម្បីធានាឲ្យស្ត្រីប្រើប្រាស់ និងអាស្រ័យផលសិទ្ធិមនុស្ស និង សេរីភាពមូលដ្ឋានដោយសមភាពជាមួយបុរស"។



# តើការបោះឆ្នោតលើកនេះមានអ្វីថ្មីទេ ?













នែនែ ៗៗ អ្នកចង់និយាយថាម៉េចហ្នឹង? មានពាក្យ
ដដែលផង មានពាក្យប្លែកផង ចង់មានន័យថាម៉េច?!



ខ្ញុំ ខ្ញុំចង់មានន័យថាដដែលហ្នឹងគឺយើង
ចូលរួមទៅបោះឆ្នោតជ្រើសតាំងតំណាង
រាស្ត្រទាំងអស់គ្នា រៀងរាល់ប្រាំឆ្នាំម្តង
ប្រាំឆ្នាំម្តង! ដូចឥឡូវជិតដល់ទៀតហើយ
ហ្នឹងមិនដដែល!...



ហើយចុះមិនឃើញមានអ្វីប្លែក
ចង់និយាយថាម៉េច?



មិនប្លែកត្រង់ចំនួនស្ត្រីជាប់ឆ្នោតនៅ
មានចំនួនតិចនៅឡើយ ត្រង់ហ្នឹង
ហើយដែលខ្ញុំថាមិនប្លែកនោះ!

ការណ៍នេះ ដោយសារតែគណបក្សនយោបាយមិនទាន់មានគោលនយោបាយជាក់លាក់ជាលាយលក្ខណ៍អក្សរក្នុងការកំណត់ស្ត្រីជាប់ឆ្នោតនៅឡើយ។ ប្រសិនបើគណបក្សនយោបាយទាំងនោះកំណត់កូតាច្បាស់លាស់ ដោយដាក់បេក្ខជនស្ត្រីឈរឈ្មោះនៅលេខរៀងខាងលើឬឆ្លាស់ស្ត្រី-បុរសយ៉ាងហោចចំនួន ៣០% នោះស្ត្រីជាប់ឆ្នោតនឹងកើនឡើងរហូតដល់គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាទៀតផង។





គណបក្សទាំងនោះហាក់យល់ស្របគ្នាថាត្រូវការបេក្ខជនស្ត្រីមាន "សមត្ថភាព" មាន "ប្រជាប្រិយភាព" មាន "អតីតភាពខាងនយោបាយ" មាន "លទ្ធភាព" និងមាន "សេចក្តីក្លាហាន"។ គណបក្សខ្លះយល់ឃើញថាការដាក់ស្ត្រីឈរឈ្មោះច្រើនគឺជា "ការលះបង់" អាចគណបក្សខ្លួនធ្លាក់ការគាំទ្រ។



ទេរឿងនេះបើតាមខ្ញុំយល់ មិនមែនគេខុសទាំងស្រុងនោះទេ គឺមកពីយើងទាំងអស់គ្នាខ្លះដែរ ពេលបោះឆ្នោតមិនបានពិនិត្យឲ្យបានច្បាស់លាស់ថាតើគណបក្សនោះមានដាក់បេក្ខជនស្ត្រីនៅជួរលើ ឬឆ្លាស់គ្នាស្ត្រីបុរសដែរទេ?



ហើយមានគោលនយោបាយជាក់លាក់គិតគូរដោះស្រាយបញ្ហាស្ត្រី និងកុមារដែរឬទេ? ដូចជាបញ្ហាជួញដូរស្ត្រី និងកុមារ បញ្ហាសុខភាព អំពើហិង្សាក្នុងគ្រួសារ ការរំលោភសេពសន្ថិវៈ ការរើសអើងក្នុងការងារ។ល។



តើគណបក្សនោះគោរព និងធ្វើតាមពាក្យសន្យារបស់ខ្លួនបានកម្រិតណា? ព្រោះយើងជាម្ចាស់ឆ្នោតយើងមានសិទ្ធិពេញលេញ មិនថាអញ្ចឹង







## តើរបៀបបោះឆ្នោតឲ្យស្ត្រីយ៉ាងដូចម្ដេច ?




លោកតា មីង ពូ! បោះឆ្នោតយ៉ាងណាទើបជាប់គណបក្សដែលមានស្ត្រីឈរឈ្មោះច្រើន?


ទី១ យើងត្រូវមើលបញ្ជីបេក្ខជនឈរឈ្មោះគណបក្សនយោបាយ ថាតើមានដាក់បេក្ខជនស្រី-ប្រុសឆ្លាស់គ្នាដែរឬទេ ពិសេសនៅជួរលើ!


រួចចុះយើងទៅមើលបញ្ជីឈ្មោះបេក្ខជននោះនៅឯណា?


យើងអាចទៅមើលបញ្ជីឈ្មោះបេក្ខជនរបស់គណបក្សនីមួយៗនៅតាម**ទីស្នាក់ការគណៈកម្មការរាជធានី/ខេត្តរៀបចំការបោះឆ្នោត (គធ/ខប)** និងនៅតាមទីប្រជុំជននានា ដូចជា ផ្សារលក់ដូរ ចាប់ពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៣ រហូតដល់ថ្ងៃបោះឆ្នោត។



- នែសំនួរក្មួយស្រីនេះល្អណាស់ ពិនិត្យយ៉ាងណាកុំឲ្យភ្លាត់ភ្លេច
- ទី២ ពិនិត្យកម្មវិធីនយោបាយ ពិសេសត្រូវចាំបណ្ដាំកុំឆោត
- តើគណបក្សណាខ្លះលើកស្ទួយស្ត្រី ធ្វើតាមសន្យាប្រាថ្នាការពារ
- នែកក្នុងអំឡុងពេលគេឃោសនា សន្យាខាងមុខបំភ្លេចពេលក្រោយ

ស្ដាប់ឲ្យជាក់ច្បាស់ជាកាតព្វកិច្ច ជាករណីយកិច្ចនៃអ្នកបោះឆ្នោត។
ឲ្យជាក់ពីឆ្ងាយចាំលៃពិសោធន៍ សម្រេចបោះឆ្នោតឲ្យស្មើភាពគ្នា។
គាំទ្រតំលៃស្ត្រីឲ្យជាក់ជា កិច្ចការធានាចាំបោះឆ្នោតឲ្យ។
ពិនិត្យសាច់ការកុំបីថ្លោះធ្លោយ ភូតភរញ៉ុយៗយើងកុំគាំទ្រ។



អញ្ចឹងលោកតា អ៊ំ ពូ លោកគ្រូ ជាពិសេសលោកពូសម តើពេលណាទើបពួកយើងបានដឹងពីកម្មវិធីនយោបាយរបស់គណបក្សដែលនិយាយអំពីសិទ្ធិស្ត្រី និងដំណោះស្រាយបញ្ហាស្ត្រី និងកុមារ?



ល្អណាស់ក្មួយ! អ្នកទាំងអស់គ្នា ត្រូវចាំថាថ្ងៃទី២៧ ខែមិថុនា រហូតដល់ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៣ គណបក្សទាំងអស់នឹងចាប់ផ្តើមធ្វើការឃោសនា បង្ហាញកម្មវិធីនយោបាយតាមប្រព័ន្ធផ្សព្វផ្សាយ វេទិកា ឯកសារបោះពុម្ពផ្សេងៗ។


- កុំភ្លេចថាបើស្ត្រីជាប់ឆ្នោតច្រើន
ជួយស្ត្រី កុមារ បុរសឲ្យបានថ្កុំថ្កើង
- ហើយម្យ៉ាងពិតជាបានដោះស្រាយ
មានតួនាទីធំៗក្នុងកម្ពុជា
ចម្រុងចម្រើនប្រទេសជាតិឡើង
លើកស្ទួយជាតិយើងបានស្មើគ្នា។
ជួយស្ត្រីទាំងឡាយឲ្យមានការងារ
ស្របតាមមាគ៌ាអភិវឌ្ឍន៍សហស្សវត្សរ៍ថ្មី។


បងប្អូន អ៊ំ ពូ មីងទាំងអស់គ្នា! បញ្ហារបស់ស្ត្រីនឹងត្រូវ
បានដោះស្រាយនៅពេលមានចំនួនស្ត្រីច្រើនចូលរួម
ក្នុងការដឹកនាំ និងការសម្រេចចិត្ត។


បន្ថែមលើនេះទៀត! នៅពេលស្ត្រីក្លាយជាអ្នកដឹកនាំ
ស្ត្រីនឹងមានឱកាស លើកឡើងពីតម្រូវការចាំបាច់របស់
ស្ត្រីដាក់ចូលទៅក្នុងគោលនយោបាយនានារបស់ជាតិ។


ហើយនឹងអាចឆ្លើយតបតម្រូវការ និងបញ្ហាស្ត្រីបាន
ព្រោះអ្នកដែលអាចមើលឃើញបញ្ហា និងដឹងពីតម្រូវ
ការចាំបាច់របស់ស្ត្រី គឺមានតែស្ត្រីខ្លួនឯងប៉ុណ្ណោះ។


អញ្ចឹង! យើងទាំងអស់គ្នាទៅបោះ-
ឆ្នោតឲ្យគណបក្សណាដែលលើក
កម្ពស់ គាំទ្រស្ត្រីមែនទេបងប្អូន!


ពិតមែនហើយ! យើងបោះឆ្នោតគាំទ្រស្ត្រី គ្រប់គ្នាៗ!

# បញ្ហារបស់ស្ត្រីនឹងត្រូវបានដោះស្រាយនៅពេល
# មានចំនួនស្ត្រីច្រើនជាថ្នាក់ដឹកនាំ និងថ្នាក់សំរេចចិត្ត

## ផលិតដោយ

ខុមហ្វ្រែល COMFREL

## ឧបត្ថម្ភដោយ

សៀវភៅរូបភាពនេះ ដកស្រង់ចេញពីវីដេអូស្ប៉ុត ( Video Spot ) របស់ខុមហ្វ្រែល ស្តីពី "បោះឆ្នោតគាំទ្រស្ត្រីជួយប្រទេសយើង"។
ប្រសិនបើអង្គការ សមាគម សហគមន៍ណាមានបំណងចង់យកសៀវភៅនេះទៅផ្សព្វផ្សាយបន្ត ឬបោះពុម្ព សូមអញ្ជើញទំនាក់ទំនងមកគណៈកម្មាធិការខុមហ្វ្រែល តាមអាសយដ្ឋានខាងក្រោមនេះ។

រៀបរៀងដោយ៖ **សឺនកេត សិរីលក្ខណ៍** អ្នកសម្របសម្រួលកម្មវិធីអប់រំ និងយេនឌ័រខុមហ្វ្រែល
ផ្តល់យោបល់ដោយ៖ **គល់ បញ្ញា** នាយកប្រតិបត្តិខុមហ្វ្រែល

**អាសយដ្ឋានស្នាក់ការកណ្តាលខុមហ្វ្រែល**

ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ កម្ពុជា
ប្រអប់សំបុត្រ ១១៤៤
ទូរស័ព្ទ ០២៣ ៨៨៤ ១៥០ អ៊ីម៉ែល comfrel@online.com.kh
ទូរសារ ០២៣ ៨៨៣ ៧៥០ គេហទំព័រ www.comfrel.org